**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្លឹបបាល់ទាត់អគ្គិសនីកម្ពុជា**
លេខ ០១៣.កប.អក

## សេចក្ដីជូនដំណឹង
## ស្ដីពី
## ការជ្រើសរើសកីឡាករ សម្រាប់ក្លឹបបាល់ទាត់អគ្គិសនីកម្ពុជា

ក្លឹបបាល់ទាត់អគ្គិសនីកម្ពុជា មានកិត្តិយសសូមជម្រាបជូន កីឡាករ និងយុវជនដែលមានទេពកោសល ខ្ពស់ក្នុងការលេងបាល់ទាត់ មេត្តាជ្រាបថាៈ ក្លឹបបាល់ទាត់អគ្គិសនីកម្ពុជា (EDC FC) ត្រូវការជ្រើសរើសកីឡាករបាល់ទាត់ ចំនួន១៥រូប ដែលមានបុគ្គលិកលក្ខណៈសម្បត្តិ ដូចខាងក្រោមៈ

- យុវជនខ្មែរ កើតនៅក្នុងឆ្នាំ ១៩៩៦ ឬ ១៩៩៧ ឬ ១៩៩៨
- មានកាយសម្បទាមាំមួន កំពស់ចាប់ពី ១.៧០ម៉ែត្រ ឡើងទៅ
- មិនមែនជាកីឡាករជាប់កុងត្រាបស់ក្លឹបបាល់ទាត់ណាមួយ
- មានភាពអំណត់ រួសរាយរាក់ទាក់ និងគោរពវិន័យ
- ចេះអាន និងសរសេរ អក្សរខ្មែរ

**សម្រាប់ប្រាក់ឧបត្ថម្ភប្រចាំខែ:**

- ស្ថិតនៅក្នុងការចរចាជាមួយក្លឹបនៅក្រោយពេលជាប់ក្នុងជម្រើស

**សម្រាប់ការដាក់ពាក្យត្រូវភ្ជាប់មកជាមួយនូវ:**

- ពាក្យស្នើសុំ — ចំនួន ០១ច្បាប់
- ប្រវត្តិរូបសង្ខេបមានបិទរូបថត ៤ x ៦ — ចំនួន ០១ច្បាប់
- (ថតចម្លង) អត្តសញ្ញាណប័ណ្ណ ឬ សំបុត្រកំណើត ឬ សៀវភៅស្នាក់នៅ ឬ លិខិតឆ្លងដែន ឬលិខិតផ្សេងៗ ដែលអាចបញ្ជាក់ពីអាយុរបស់សាមីខ្លួន — ចំនួន ០១ច្បាប់

**ឯកសារដែលត្រូវបំពេញបន្ថែមនៅក្រោយពេលជាប់ក្នុងជម្រើស:**

- កិច្ចសន្យាការងារ — ចំនួន ០១ច្បាប់
- សេចក្ដីចម្លង អត្តសញ្ញាណប័ណ្ណ ឬ សំបុត្រកំណើត ឬសៀវភៅស្នាក់នៅ ឬ លិខិតឆ្លងដែន ឬលិខិតផ្សេងៗ ដែលអាចបញ្ជាក់ពីអាយុរបស់សាមីខ្លួន — ចំនួន ០១ច្បាប់
- លិខិតបញ្ជាក់កិរិយាមាយាទ — ចំនួន ០១ច្បាប់
- លិខិតបញ្ជាក់សុខភាព — ចំនួន ០១ច្បាប់

**កាលបរិច្ឆេទ និងទីកន្លែងទទួលពាក្យ:** ការិយាល័យរដ្ឋបាល នៃនាយកដ្ឋានរដ្ឋបាល អគ្គិសនីកម្ពុជា រៀងរាល់ម៉ោងធ្វើការ ចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៦ ។

- ពេលព្រឹក ចាប់ពីម៉ោង ០៨ : ៣០ ដល់ម៉ោង ១១ : ៣០
- ពេលល្ងាច ចាប់ពីម៉ោង ១៤ : ៣០ ដល់ម៉ោង ១៧ : ០០ ។

យុវជន ឬ កីឡាករ ដែលមានចំណាប់អារម្មណ៍ចង់ក្លាយខ្លួនជាកីឡាកររបស់ក្លឹបបាល់ទាត់អគ្គិសនីកម្ពុជា អាចមកទំនាក់ទំនងសាកសួរព័ត៌មានបានដោយផ្ទាល់នៅការិយាល័យរដ្ឋបាល នៃនាយកដ្ឋានរដ្ឋបាល អគ្គិសនីកម្ពុជា: #២ ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ក្បែរវត្តភ្នំ រៀងរាល់ម៉ោងធ្វើការ ។

រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦

**ប្រធានគណៈកម្មការប្រតិបត្តិ និងគ្រប់គ្រង**
**ក្លឹបបាល់ទាត់អគ្គិសនីកម្ពុជា**

លី គីឃា

**ទូរស័ព្ទទំនាក់ទំនង:**

លោក សាន្ត សុខរក្សា : ០៩២ ៨៧៧ ៨២២
លោក ឈួន សុខណា : ០៦៩ ៧៥៥ ៧៧៥